# BACCALAURÉAT GÉNÉRAL

**SESSION 2016**

**CAMBODGIEN**

**VENDREDI 17 JUIN 2016**

LANGUE VIVANTE **1**

Série **L –** Durée de l'épreuve : **3 heures** – coefficient : **4**

Séries **ES-S** – Durée de l'épreuve : **3 heures** – coefficient : **3**

**Le candidat traitera, dans la langue étrangère, l'ensemble des questions de l'épreuve pour laquelle il compose.**

*L'usage des calculatrices électroniques et du dictionnaire est interdit.*

Dès que ce sujet vous est remis, assurez-vous qu'il est complet.
Ce sujet comporte 4 pages numérotées de 1/4 à 4/4.

**Répartition des points**

| | |
|---|---|
| Compréhension de l'écrit | 10 points |
| Expression écrite | 10 points |

ជីវិតសត្វលោក ដែលរស់នៅតាមបែបធម្មជាតិនោះ តែងមានអាវុធសម្រាប់ការពារខ្លួន តទល់ជាមួយសត្រូវ ដែលបានមកបៀតបៀននិងយាយីរំខាន នូវសេចក្ដីសុខសាន្តរបស់ខ្លួនដែរ ។ ប៉ុន្តែ បើសត្វលោកមានលក្ខណៈស្លូតពេក តែងត្រូវបានគេធ្វើបាបនិងជិះជាន់ទៅតាមទំនើងចិត្តរបស់គេ ឬរបស់សត្វ ដែលមានកម្លាំងជាងខ្លួនពិតប្រាកដ ។

បើគេពិនិត្យអំពីសរីរាង្គកាយរបស់សត្វតាមដំណើរនៃធម្មជាតិតាក់តែងមកនោះ ដូចជាសត្វខ្លះមានធ្មេញនិងចង្កូម ព្រមទាំងក្រចកដ៏មុតស្រួច សម្រាប់ការពារខ្លួនតទល់ ឬប្រឈមមុខនឹងសត្រូវរបស់វាផង និងសម្រាប់ស្វែងរកចំណីអាហាររបស់វាផង ។ សត្វខ្លះទៀត អាងកម្លាំងរបស់ខ្លួន ក្នុងការរឹបនិងលេប ដូចពស់ថ្លាន់ជាដើម ។ សត្វខ្លះទៀត អាងចំពុះ និងអាងខ្នាយ ព្រមទាំងមានពិស តាមរយៈការចឹកឬខាំនិងការព្រួសពិស... ។ល។ ទាំងអស់នេះ គេសម្គាល់ឃើញថា ធម្មជាតិនៃសត្វភាគច្រើន តែងមានអាវុធសម្រាប់ការពារខ្លួនឯងផង និងសម្រាប់ចាប់ចំណីអាហារ ដើម្បីបានរស់ផង ។ ប៉ុន្តែមានសត្វល្ងង់ខ្លះ មិនមានពិសក្នុងការខាំឬចឹកមនុស្សនោះទេ គេហៅថា ជាសត្វស្លូត ដូចពស់ព្រលឹតជាដើម ។ ឯប្រការសំខាន់គ្រប់យ៉ាងទៀតនោះ ពស់ព្រលឹតក៏មានការរីកចម្រើនជំពាត់ តាមរយៈការបញ្ចេញអំណាចក្នុងការចាប់ចំណីរបស់វា ដូចជាការចាប់កូនត្រីនិងកំពឹស... ។

ដោយឡែក សម្រាប់មនុស្សនិងមនុស្សវិញ ក៏គេតែងនិយាយថា អ្នកដែលមានចរិតស្លូតពេកនោះ ក៏រកសេចក្ដីសុខឲ្យខ្លួនឯង មិនបានផងដែរ ។ ពាក្យចាស់បានបញ្ជាក់ថា ៖ « តម្រិះជាអាហារ បញ្ញាជាអាវុធ » និងមានសុភាសិតបុរាណមួយឃ្លា ពោលថា ៖ « ស្លូតស្លាប់ វៀចវេរមានភ័ព្វ អាយុយឺនយូរ » ឬ « ផ្លូវវៀចកុំបោះបង់ ផ្លូវណាត្រង់កុំដើរហោង » ដើម្បីទុកឲ្យកូនចៅបន្តគ្រប់ជំនាន់ទាំងអស់ មានការពិចារណាក្នុងការការពារខ្លួន ឬនៅពេលប្រឈមមុខតទល់ជាមួយសត្រូវឈ្លានពាននិងរំលោភបំពានលើសិទ្ធិសេរីភាពរបស់ខ្លួនជាដើម ។

តាមរយៈរឿងនិទានអំពីនាគតាំងសីល នៅក្នុងសៀវភៅ **មួយជំហានម្ដង** របស់សម្ដេចព្រះមហាឃោសានន្ទ ទំព័រទី ១០ បានបញ្ជាក់ថា ៖ នាគនោះស្លូតពេក ព្រោះកំពុងប្រព្រឹត្តធម៌សង្រួមកាយចិត្ត ។ ពេលនោះ មានក្មេងគង្វាលគោ ចេះតែធ្វើបាបឡើងច្រំនិងជិះជាន់ពីលើ ហើយបានយកអាចម៍គោបញ្ចុកមាត់ផង ។ ក្រោយមក នាគនោះបានជួបនឹងព្រះពោធិសត្វ ។ ព្រះពោធិសត្វបានប្រាប់ថា ស្លូតពេកមិនអាចរកបានសេចក្ដីសុខឲ្យខ្លួនបាននោះទេ គឺលុះត្រាតែបញ្ចេញអាវុធ ដូចជាការព្រួសពិសភ្លើង និងមានការគ្រញែងខ្លួនហាក់មានកំហឹងទៅក្មេងឃ្វាលគោ ក្នុងពេលវាធ្វើបាបខ្លួននោះ ទើបវាលែងហ៊ានមកបៀតបៀនទៀត ។ នេះហើយ ដែលជាមធ្យោបាយ ដើម្បីឲ្យមានសេចក្ដីសុខសាន្តក្នុងការចម្រើនធម៌ទៅមុខទៀត ។ ប៉ុន្តែចំពោះអាកប្បកិរិយានៃការកំញើញទៅក្មេងគង្វាលគោនោះ វាគ្រាន់តែជាសិល្បៈក្នុងការសម្ដែងប៉ុណ្ណោះ ពោលគឺមិនមែនជាកំហឹងតទល់ ដែលផ្ទុះចេញពីក្នុងចិត្តនោះឡើយ ។

ផ្ដើមចេញពីការរៀបរាប់ខាងលើនេះ បើនិយាយអំពីសង្គមជាតិយើងវិញ ក៏ដូចជាប្រទេសដទៃទៀតនៅលើលោកនេះដែរ តែងមានកងកម្លាំងប្រដាប់អាវុធនេះហើយ ដែលជាអាវុធសម្រាប់ការពារបូរណភាពទឹកដី និងជានាទូរភាពសុខសាន្ត ព្រមទាំងការអភិវឌ្ឍរបស់ជាតិនោះ ។ ល្អិកណាមានអំពើរំលោភបំពាន ឬជាការឈ្លានពានទឹកដី បានសេចក្ដីថា យើងមិនទ្រាំធ្វើស្លូតឲ្យស្លាប់នោះទេ គឺល្អិកនោះហើយ ដែលជាតួនាទីរបស់អ្នកការពារ ត្រូវបានសម្ដែងតួ តាមរយៈការបង្ហាញនូវទឹកចិត្តការពារជាតិ ដ៏អង់អាច ក្លាហានមោះមុតបំផុត ។

សរុបមក យើងស្លូត គឺ យើងមិនមានការរំលោភបំពានទឹកដីរបស់គេមែន តែក៏យើងមិនបណ្ដោយឲ្យគេរំលោភបំពានយកទឹកដីយើងនោះដែរ ។ យើងប្ដេជ្ញាការពារទឹកដីឲ្យបានគង់វង្សជារៀងរហូត ៕

**« ទស្សនៈ ៖ ស្លូតពេក គេជាន់ ! » ដោយ លី ហាក់សេង កម្ពុជាថ្មី ប្រចាំថ្ងៃ ២៧ មិថុនា ២០១៥ ។**

## Vocabulaire ~ វាក្យសព្ទ

៙ កំញើញ ៖ faire des gestes menaçants ; montrer les dents
៙ ខ្នាយ ៖ ergot(s) (d'un coq) ; défense(s) d'un sanglier
៙ គង្វាល ៖ gardien d'animaux
៙ គ្រញៀងខ្លួន ៖ ញាក់ទទាក់ខ្លួនដោយព្រឺ, ដោយស្ញើប, ដោយខឹងខ្លាំងណាស់
៙ ឃ្វាល ៖ garder des animaux domestiques, faire paître des animaux domestiques
៙ ចរិត ៖ caractère
៙ ចម្រើនធម៌ ៖ observer le Dharma
៙ ជាតិ ៖ nation ; national ; nature
៙ តម្រិះ ៖ réflexion, pensée
៙ តួនាទី ៖ rôle
៙ តាំងសីល ៖ suivre les préceptes religieux
៙ ធម្មជាតិ ៖ nature
៙ នាគ ៖ *nāga*, *sorte de serpent mythique*
៙ បូរណភាព ៖ intégrité
៙ ប្ដេជ្ញា ៖ s'engager à
៙ ប្រព្រឹត្តធម៌ ៖ observer le Dharma
៙ ពស់ថ្លាន់ ៖ python
៙ ពស់ព្រលឹត ៖ serpent à tentacules, *sorte de serpent aquatique non venimeux*
៙ ពិស ៖ venin
៙ ពោធិសត្វ ៖ អ្នកដែលមានចិត្តឬមានសេចក្ដីប្រាថ្នាជាប់នៅក្នុងពោធិ គឺអ្នកដែលកំពុងខំប្រឹងបំពេញបារមីបម្រុងនឹងបានត្រាស់ជាព្រះសម្មាសម្ពុទ្ធ, bodhisattva
៙ មោះមុត ៖ audacieux, sans peur
៙ លក្ខណៈ ៖ caractéristique(s)
៙ ល្ពឹកណា ... ល្ពឹកនោះ ... ៖ tant que ; dans le cas où, s'il arrivait que
៙ សង្រួម ៖ faire attention à fermer son esprit pour que les sentiments qui viennent de l'activité des sens ne troublent pas la conscience causant des désirs de cupidité, de ressentiment
៙ សង្រួមកាយ ៖ mettre le corps en état de se concentrer
៙ សង្រួមចិត្ត ៖ se concentrer psychiquement
៙ យាយី ៖ បៀតបៀន, ជន្លជន្លេញ, បន្លាច
៙ សង្គម ៖ société ; social
៙ សត្រូវ ៖ អ្នកបៀតបៀនគេ, ខ្មាំង
៙ សត្វលោក ៖ les êtres vivants
៙ សត្វល្មូន ៖ សត្វលូន, reptile
៙ សម្ដេចព្រះមហាឃោសានន្ទ ៖ le vénérable Mahā Ghosānanda
៙ សម្ដែងតួ ៖ jouer un rôle
៙ សរីរាង្គ ៖ organe
៙ សរីរាង្គកាយ ៖ corps, organisme
៙ សិទ្ធិ ៖ droit(s)
៙ សិល្បៈ ៖ art, artifice
៙ សុភាសិត ៖ proverbe
៙ សេរីភាព ៖ liberté
៙ ស្លូត ៖ doux, gentil, docile, inoffensif
៙ អភិវឌ្ឍ ៖ développer ; se développer
៙ អាកប្បកិរិយា ៖ attitude
៙ អាចម៍ ៖ (អានថា អាច់)
៙ អាវុធ ៖ arme

## TRAVAIL À FAIRE PAR LE CANDIDAT

### I. COMPRÉHENSION DE L’ÉCRIT : (10 points)

**១.ក-** តើសត្វមានអាវុធអ្វីខ្លះ ដើម្បីការពារខ្លួន និងស្វែងរកចំណី ? (២ ពិន្ទុ)

**១.ខ-** តើពស់ថ្លាន់ និង ពស់ព្រលឹត ជាសត្វដែលមានលក្ខណៈរៀង ៗ ខ្លួនអ្វីខ្លះ ? (២ ពិន្ទុ)

**១.គ-** ហេតុអ្វីបានជានាគមិនអាចប្រព្រឹត្តធម៌សង្រួមកាយចិត្តយ៉ាងសុខសាន្តបាន ? (២ ពិន្ទុ)

**១.ឃ-** តើព្រះពោធិសត្វបានទូន្មាននាគឲ្យព្រួសពិសភ្លើង ដើម្បីសម្លាប់ក្មេងគង្វាលគោ មែនឬ ? (២ ពិន្ទុ)

**១.ង-** សរុបមក បើយើងស្លូត តើមានន័យដូចម្ដេច ? (២ ពិន្ទុ)

### II. EXPRESSION ÉCRITE : (10 points)

**Afin de respecter l’anonymat de votre copie, vous ne devez pas signer votre composition, citer votre nom, celui d’un camarade ou celui de votre établissement.**

Les candidats traitent les **<u>DEUX</u>** questions (120 mots minimum pour chaque question)

**២.ក-** នៅក្នុងប្រទេសមួយចំនួន ដល់ធំពេញវ័យ កំលោះគ្រប់ ៗ រូបត្រូវចូលធ្វើទាហានបម្រើជាតិ អស់រយៈពេល ២-៣ ឆ្នាំ ។ ក្នុងប្រទេសខ្លះទៀត ក្រមុំ ៗ ក៏ត្រូវចូលធ្វើទាហានមួយគ្រាដែរ ។ ចំណែកឯនៅប្រទេសបារាំងសព្វថ្ងៃនេះ ក៏ដូចនៅប្រទេសកម្ពុជាដែរ លែងមានការចូលធ្វើទាហានដោយបង្ខំនោះតទៅទៀតហើយ ។ តើអ្នកគិតថា វាមានប្រយោជន៍ ឬក៏ពុំមានប្រយោជន៍អ្វីខ្លះ ? ចូរបញ្ជាក់ឲ្យបានក្បោះក្បាយ ។ (៥ ពិន្ទុ)

**២.ខ-** បើមានមនុស្សម្នាក់ ចេះតែមកឈ្លានពាន រំខាន និងយាយីអ្នក តើអ្នកនឹងមានប្រតិកម្មនិងប្រើមធ្យោបាយអ្វីខ្លះ ដើម្បីរកការស្រុះស្រួលគ្នា ? ចូរបញ្ជាក់ឲ្យបានក្បោះក្បាយ ៕ (៥ ពិន្ទុ)